# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ០៧៩ / គ.ជ.ប
/០៧

## សេចក្តីណែនាំ

### ស្តីពីការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងពិនិត្យផ្ទៀងផ្ទាត់ ឯកសារបញ្ជាក់អត្តសញ្ញាណជាមួយបញ្ជីឈ្មោះអ្នកបោះឆ្នោត

យោង : - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។
- បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ ។
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ ។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

សូមណែនាំដល់អស់លោក លោកស្រីប្រធាន គខ/គប ចាត់ចែងអនុវត្តការងារតាមខ្លឹមសារ ដូចខាងក្រោម ៖

I- ណែនាំដល់ក្រុមបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតឱ្យអនុវត្ត និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដូចខាងក្រោម ៖

១- មុននឹងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត អ្នកចែកប័ណ្ណ ត្រូវពិនិត្យឈ្មោះឱ្យបានច្បាស់លាស់ ប្រសិនបើ ឈ្មោះដូចគ្នា ឬ ស្រដៀងគ្នាត្រូវផ្ទៀងផ្ទាត់ទិន្នន័យដទៃទៀត ដើម្បីឱ្យប្រាកដថាឈ្មោះណាមួយជារបស់សាមីខ្លួនពិតប្រាកដ ។

២- ត្រូវជម្រាបដល់ប្រជាពលរដ្ឋឱ្យផ្ទៀងផ្ទាត់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណដែលគាត់មាន និងដែលត្រូវប្រើប្រាស់នៅពេលបោះឆ្នោត ហើយសូមឱ្យយកប័ណ្ណព័ត៌មាននេះ ទៅជាមួយផង ។

៣- ប្រសិនបើឈ្មោះនោះ ប្រាកដជាឈ្មោះរបស់គាត់ ហើយមានខុសអក្ខរាវិរុទ្ធ ឬទិន្នន័យបន្តិចបន្តួចត្រូវជម្រាបគាត់ថា ឯកសារបញ្ជាក់អត្តសញ្ញាណនោះ អាចប្រើប្រាស់សម្រាប់ការបោះឆ្នោតបាន ។

II- ណែនាំដល់ គយ/សប ឱ្យផ្សព្វផ្សាយ និងណែនាំដល់ គ.ក.ប ក្នុងការផ្ទៀងផ្ទាត់ឈ្មោះអ្នកបោះឆ្នោតជាមួយឯកសារបញ្ជាក់អត្តសញ្ញាណឱ្យបានត្រឹមត្រូវ នៅពេលបោះឆ្នោត ៖

១- ប្រសិនបើ នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតមានឈ្មោះអ្នកបោះឆ្នោតដូចគ្នា ឬស្រដៀងគ្នាត្រូវផ្ទៀងផ្ទាត់ទិន្នន័យដទៃទៀត ដើម្បីឱ្យប្រាកដថា ឈ្មោះណាមួយជារបស់សាមីខ្លួនពិតប្រាកដ ។

២- ប្រសិនបើ ឈ្មោះនោះជាឈ្មោះរបស់គាត់ពិតប្រាកដ ប៉ុន្តែមានខុសអក្ខរាវិរុទ្ធ ឬទិន្នន័យបន្តិចបន្តួចត្រូវអនុញ្ញាតឱ្យគាត់បោះឆ្នោតបាន ។

ទទួលបានសេចក្តីណែនាំនេះ សូមអស់លោក លោកស្រី ប្រធាន គខ/គប ក្រុមបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គយ/សប និង គ.ក.ប យកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អ៊ឹម សួស្តី